ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី ប៊ុន ហុន

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង វណ្ណៈ

២-មេធាវី អ៊ឹង គីរិយា

៣-មេធាវី កែត ឃី

៤-មេធាវី អ៊ីវ ប៉ូលី

៥-មេធាវី ខៀវ សំបូរ

៦-មេធាវី ជា សុកនួន

៧-មេធាវី សាន់ ជួយ

៨-មេធាវី ថាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាឡា

១១-មេធាវី ម៉ី ឧសភា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លីវ សុវណ្ណា

១៤-មេធាវី ឈីវ តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មានន្ទ

១៧-មេធាវី អ៊ូ ធីតាពៅ

១៨-មេធាវី លី ពីង

១៩-មេធាវី ឃីម វិសុត្រ

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កែ វិសាល

២២-មេធាវី ហូ លីហួច

២៣-មេធាវី វ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុន វិមានចំប៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ: ០៤៧៥ /សសគម/១៦

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកុម្ភៈ ឆ្នាំ២០១៦

# សេចក្តីសម្រេច

## ស្តីពី

## ការតែងតាំងអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី

## ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨៩៥/០៦ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលក្ខន្តិកៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញបទបញ្ជាផ្ទៃក្នុងគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ១៩៩៥
- បានឃើញក្រមសីលធម៌មេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០១២
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការបោះឆ្នោតជ្រើសតាំងលោកមេធាវី **ប៊ុន ហុន** ជាប្រធានគណៈមេធាវីអាណត្តិទី ១០
- បានឃើញកំណត់ហេតុនៃមហាសន្និបាតគណៈមេធាវី ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៥ ស្តីពីការបោះឆ្នោតជ្រើសតាំងសមាជិក-សមាជិកាក្រុមប្រឹក្សាគណៈមេធាវីអាណត្តិទី ៨
- បានឃើញសេចក្តីសម្រេចលេខ ០០១/សសគម/១៣ ចុះថ្ងៃទី០៤ ខែមករា ឆ្នាំ២០១៣ របស់គណៈមេធាវី ស្តីពីការតែងតាំងអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី
- បានឃើញសំណើរបស់សាមីខ្លួន ចុះថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០១៦។

## ស ម្រេ ច

**ប្រការ ១.-** តែងតាំងលោកស្រីមេធាវី **ឃីម ថាវី** អត្តលេខ **៤២៤** ជាអធិការនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវី។

**ប្រការ ២.-** លោកស្រីមេធាវី **យឹម ថាវី** មានភារកិច្ចដូចខាងក្រោម ៖

-ពិនិត្យ តាមដាន លើគ្រប់សកម្មភាពរំលោភលើវិធានវិជ្ជាជីវៈមេធាវី ពីសំណាក់សមាជិក-សមាជិកាគណៈមេធាវី និងពីសំណាក់បុគ្គលដទៃទៀត តាមការចាត់តាំងរបស់ប្រធានគណៈ-មេធាវី

-ត្រូវរាយការណ៍ជាសម្ងាត់ ឬ ជាលាយលក្ខណ៍អក្សរ ភ្ជាប់ដោយភស្តុតាងមកប្រធានគណៈ-មេធាវី ដើម្បីដាក់ជូនក្រុមប្រឹក្សាគណៈមេធាវីពិនិត្យ និងសម្រេច

-ទទួលភារកិច្ចផ្សេងៗទៀត ដែលត្រូវបានចាត់តាំងដោយប្រធានគណៈមេធាវី ។

**ប្រការ ៣.-** លោកស្រីមេធាវី **យឹម ថាវី** ត្រូវទទួលខុសត្រូវចំពោះមុខប្រធាន និងក្រុមប្រឹក្សាគណៈមេធាវី លើសកម្មភាព និងលទ្ធផលការងាររបស់ខ្លួន ។

**ប្រការ ៤.-** បទប្បញ្ញត្តិទាំងឡាយដែលមានខ្លឹមសារផ្ទុយពីសេចក្តីសម្រេចនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៥.-** អគ្គលេខាធិការ អគ្គហេរញ្ញិក ប្រធាននាយកដ្ឋានអធិការកិច្ច និងសាមីខ្លួន ត្រូវអនុវត្តសេចក្តីសម្រេចនេះ តាមមុខការរៀងៗខ្លួន ៕

**មេធាវី. ប៊ុន-ហុន**

**ចម្លងជូន :**

-ឯកឧត្តមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍

-ក្រុមប្រឹក្សាគណៈមេធាវី

*"ដើម្បីជូនជ្រាប"*

-ដូចប្រការ ៥

-ឯកសារ-កាលប្បវត្តិ

ឥណ្ឌៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា
ចូល
-លេខ: ៥៤០
-ម៉ោង: ១០.៣០
-ថ្ងៃ ខែ ឆ្នាំ: ០៤.០២.១៦
-បញ្ជូន:

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

នាងខ្ញុំ **យឹម ថាវី** អត្តលេខ ៤២៤ ។

**សូមគោរព**

**លោកប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**កម្មវត្ថុ:** ស្នើសុំបំពេញមុខងារជាសមាជិកនៃនាយកដ្ឋានអធិការកិច្ចគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។

តបតាមកម្មវត្ថុ និងយោងខាងលើនាងខ្ញុំ សូមអនុញ្ញាត្ត លោកប្រធាន មេត្តាជ្រាបថាៈ ដោយមានបំណងដើម្បីរួមចំណែកអនុវត្តនូវសកម្មភាពជាអធិការកិច្ច ព្រមទាំងបង្កើននូវប្រសិទ្ធខ្ពស់ក្នុងការប្រកបលើជំនាញវិជ្ជាជីវៈជាមេធាវីរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។ ទន្ទឹមនឹងនេះដែរដោយរូបនាងខ្ញុំមានលក្ខណៈសម្បត្តិ និងពេលវេលាគ្រប់គ្រាន់សម្រាប់បម្រើនូវកាតព្វកិច្ចនៃការបំពេញបេសកម្មនេះ។

អាស្រ័យដូចបានជម្រាបជូនខាងលើ នាងខ្ញុំពេញចិត្តស្នើសុំបំពេញមុខងារជាសមាជិកនៃនាយកដ្ឋានអធិការកិច្ច នៃគណៈមេធាវីព្រះរាជាណាចក្រកម្ពុជា ដោយក្តីអនុគ្រោះ ។

សូមលោកប្រធានទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីនាងខ្ញុំ។

ភ្នំពេញថ្ងៃទី 04 ខែ កុម្ភៈ ឆ្នាំ 2016

04/02/16

ប៊ុន ណារិទ្ធ

04-02-16

ព្រះរាជាណាចក្រកម្ពុជា មេធាវី AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

មេធាវី.យឹម ថាវី

សាន សុធន

05-02-16

មេធាវី.ប៊ុន_ហុន